# សេចក្ដីជូនដំណឹងដល់សិក្ខាកាមដែលមានផ្ទៃពោះទាំងអស់

**ពត៌មានសំខាន់**

- ច្បាប់របស់ប្រទេសជប៉ុនគឺមិនមានការបញ្ឈប់ការងារចំពោះស្រ្តីមានផ្ទៃពោះចេញពីការងារទេ។
- **ក្រុមហ៊ុនបញ្ជូនពលករឬសហជីពគឺមិនអាចបង្ខំអោយសិក្ខាកាមវិលត្រលប់ទៅមាតុភូមិវិញដោយហេតុផលមានផ្ទៃ**ពោះបានទេ។
- ប្រសិនបើលើថានឹងមានការបញ្ឈប់ការងារអោយវិលត្រលប់ទៅមាតុភូមិវិញនោះ**សូមពិគ្រោះយោបល់ជាមួយអង្គការហ្វឹកហ្វឺនបច្ចេកទេសនឹងជំនាញ(OTIT)**។ OTITនឹងជួយអ្នក។ ※សូមមើលការទំនាក់ទំនងនៅខាងក្រោយ

## ប្រសិនបើមានផ្ទៃពោះតើគួរធ្វើដូចម្ដេចទើបល្អ？

☑ ប្រសិនបើអ្នកដឹងថាខ្លួនមានផ្ទៃពោះ សូមផ្ដល់ពត៌មានទៅខាងពិគ្រោះយោបល់ឬអ្នកទទួល បន្ទុកនៅកន្លែងធ្វើការរបស់អ្នក។

☑ ខាងអង្គការហ្វឹកហ្វឺនបច្ចេកទេសនឹងជំនាញរួមទាំងទីស្ដីការពិគ្រោះយោបល់នៅកន្លែងដែលអ្នករស់នៅក៏អាចពិគ្រោះយោបល់បានផងដែរ។

※សូមមើលការទំនាក់ទំនងនៅខាងក្រោយ

☑ សូមទៅចុះឈ្មោះអំពីការមានផ្ទៃពោះរបស់អ្នកនៅសង្កាត់ក្រុងដែលអ្នករស់នៅ។

☑ អ្នកនឹងទទួលបានសៀវភៅតាមដានសុខភាពម្ដាយកូន នឹងកាតពិនិត្យផ្ទៃពោះរយះពេលអ្នកពពោះ ពីខាងសាលាក្រុងសង្កាត់ ហើយត្រូវទៅពិនិត្យផ្ទៃពោះអោយបានទៀងទាត់។

## ប្រសិនបើមានផ្ទៃពោះតើអាចធ្វើការបានដែរឬទេ？

☑ នៅប្រទេសជប៉ុនគឺមិនមានច្បាប់បញ្ឈប់ការងារដោយសារការមានផ្ទៃពោះទេ។ទោះបីយើងមានផ្ទៃពោះ ប្រសិនបើសិក្ខាកាមមានបំណងចង់ធ្វើការងារបន្តគឺអាចធ្វើការងារបាន។

☑នៅប្រទេសជប៉ុនគឺអាចឈប់សម្រាកពីការងារ ៦ សប្ដាហ៍មុនសម្រាលកូនផងដែរ។

> ប្រសិនបើអ្នកមិនទទួលបានប្រាក់ខែក្នុងអំឡុងពេលឈប់សម្រាកពីការងារគឺអ្នកអាចទទួលប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់អ្នក (ជាមធ្យមប្រហែល ៦០ ភាគរយនៃប្រាក់ខែរបស់អ្នក) ។

## តើអាចបន្តធ្វើការបន្ទាប់ពីការសម្រាលកូនបានដែរឬទេ?

☑ដើម្បីការពារសុខភាពរាងកាយរបស់ម្ដាយ គោលការណ៍នៃប្រទេសជប៉ុនគឺតម្រូវអោយម្ដាយសម្រាកការងាររយះពេល ៨ សប្ដាហ៍ បន្ទាប់ពីសម្រាលកូនរួច។ក្រោយមកទើបអាចបន្តការងារបានទៀត។

> ប្រសិនបើអ្នកមិនទទួលបានប្រាក់ខែក្នុងអំឡុងពេលឈប់សម្រាកពីការងារគឺអ្នកអាចទទួលប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់អ្នក (ជាមធ្យមប្រហែល ៦០ ភាគរយនៃប្រាក់ខែរបស់អ្នក) ។

☑ប្រសិនបើអ្នកបានព្យួរការហ្វឹកហ្វឺនរបស់អ្នកដើម្បីទៅសម្រាលកូននៅមាតុភូមិអ្នកក៏អាចវិលត្រលប់មកជប៉ុនវិញដើម្បីបន្តធ្វើជាសិក្ខាកាមវិញបានដែរ។ (តែត្រូវការរៀបចំឯកសារបញ្ជាក់)

☑ ដើម្បីបន្តធ្វើជាសិក្ខាកាមវិញបានគឺត្រូវការរៀបចំឯកសារបញ្ជាក់នៅអង្គការហ្វឹកហ្វឺនបច្ចេកទេសនឹងជំនាញ។ សូមផ្ដល់ដំណឹងអោយច្បាស់លាស់ដល់សហជីបនឹងកន្លែងធ្វើការរបស់អ្នកអំពីពេលវេលាដែលអាចបន្តធ្វើការជាសិក្ខាកាមវិញផង។

**ពត៌មានសំខាន់**

# កន្លែងផ្តល់ពត៌មាន

## ប្រសិនបើអ្នកមានបញ្ហាសូមពិភាក្សាជាមួយអង្គការហ្វឹកហ្វឺនច្នេកទេសនឹងជំនាញ(OTIT) (ក៏អាចពិគ្រោះយោបល់តាមប្រព័ន្ធទូរស័ព្ទអ៊ីមែលបាន)

| មានភាសា | ទំនាក់ទំនងពេល | លេខទូរសព្ទ័ | OTIT គេហទំព័រជាភាសាកំណើត |
|---|---|---|---|
| ភាសាវៀតណាម | ច័ន្ទ〜សុក្រ សៅរ៏<br>១១:០០〜១៩:០០<br>(សៅរ៏ ： ៩:០០〜១៧:០០) | ០១២០-២៥០-១៦៨ | https://www.support.otit.go.jp/soudan/vi/ |
| ភាសាចិន | ច័ន្ទ ពុធ សុក្រ<br>១១:០០〜១៩:០០ | ០១២០-២៥០-១៦៩ | https://www.support.otit.go.jp/soudan/cn/ |
| ភាសាឥណ្ឌូនេស៊ី | អង្គារ ព្រហស្បត៏ សៅរ៏<br>១១:០០〜១៩:០០<br>(សៅរ៏ ： ៩:០០〜១៧:០០) | ០១២០-២៥០-១៩២ | https://www.support.otit.go.jp/soudan/id/ |
| ភាសាហ្វីលីពីន | អង្គារ ព្រហស្បត៏ សៅរ៏<br>១១:០០〜១៩:០០<br>(សៅរ៏ ： ៩:០០〜១៧:០០) | ០១២០-២៥០-១៩៧ | https://www.support.otit.go.jp/soudan/phi/ |
| ភាសាអង់គ្លេស | អង្គារ ព្រហស្បត៏ សៅរ៏<br>១១:០០〜១៩:០០<br>(សៅរ៏ ： ៩:០០〜១៧:០០) | ០១២០-២៥០-១៤៧ | https://www.support.otit.go.jp/soudan/en/ |
| ភាសាថៃ | ព្រហស្បត៏ អាទិត្យ<br>១១:០០〜១៩:០០<br>(សៅរ៏ ： ៩:០០〜១៧:០០) | ០១២០-២៥០-១៩៨ | https://www.support.otit.go.jp/soudan/th/ |
| ភាសាខ្មែរ | ព្រហស្បត៏<br>១១:០០〜១៩:០០ | ០១២០-២៥០-៣៦៦ | https://www.support.otit.go.jp/soudan/kh/ |
| ភាសាមីយ៉ាន់ម៉ា | អង្គារ<br>១១:០០〜១៩:០០ | ០១២០-២៥០-៣០២ | https://www.support.otit.go.jp/soudan/mm/ |

## ប្រសិនបើមានការព្រួយបារម្ភអំឡុងពេលមានផ្ទៃពោះឬមានបញ្ហាក្នុងការរស់នៅអាចពិគ្រោះយោបល់នៅកន្លែងពិគ្រោះយោបល់ដែលមាននៅក្នុងតំបន់ដែលអ្នករស់នៅ។

| | |
|---|---|
| កន្លែងពិគ្រោះយោបល់នៅក្នុងតំបន់<br>(គេហទំព័រគាំទ្រការរស់នៅដល់ជនបរទេស) | http://www.moj.go.jp/isa/content/930004512.pdf<br>※នៅតាមកន្លែងពិគ្រោះយោបល់នីមួយៗគឺមិនអាអាចប្រើប្រាស់ភាសាទាំងអស់បានទេ |
| កន្លែងពិគ្រោះយោបល់ដែលអាចប្រើប្រាស់ច្រើនភាសា<br>(一財) ក្រុមប្រឹក្សាអាជ្ញាធរមូលដ្ឋានអន្តរជាតិ | http://www.clair.or.jp/j/multiculture/association/consultation_list.html |

មានពត៌មានទាក់ទងអំពី 「ការរស់នៅ ・ ការស្វែងរកការងារធ្វើ」 ការសម្រាលកូននឹងការចិញ្ចឹមកូនផងដែរ

**http://www.moj.go.jp/isa/support/portal/index.html**

មានភាសា ៖ ជប៉ុន (ភាសាជប៉ុនងាយស្រួលយល់) អង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ ព័រទុយហ្គាល់ វៀតណាម នេប៉ាល់ ថៃ ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ខ្មែរ(កម្ពុជា) ហ្វីលីពីន ម៉ុងហ្គោលី ទួរគី អ៊ុយក្រែន

**ការិយាល័យអន្តោប្រវេសន៍ ក្រសួងសុខាភិបាលការងារ អង្គការហ្វឹកហ្វឺនបច្ចេកទេស**